SUPREME JUDICIAL COURT
BOSTON, MASSACHUSETTS 02108

ថ្ងៃទី7 ខែកុម្ភៈ ឆ្នាំ2019

Address 1
Address 2
Address 3

ជូនចំពោះ

ខ្ញុំជាចៅក្រមម្នាក់នៃតុលាការកំពូលដែលជាតុលាការខ្ពស់បំផុតនៅក្នុងរដ្ឋម៉ាស្សាជូសេត្ស៍។ ខ្ញុំកំពុងតែសរសេរមកជំរាបលោក-អ្នកឱ្យបានជ្រាបថា តុលាការនេះបានលុបចោលនូវការផ្តន្ទាទោសខ្លះ ឬការជំរះទោសដទៃទៀតប្រឆាំងនឹងលោក-អ្នក ហើយតុលាការនេះបានលើកបណ្ដឹងផងដែរនូវការចោទប្រកាន់នានាដែលនៅចំពោះមុខ។ ការលើកនូវការផ្តន្ទាទោសនោះត្រូវបានគេបង្ហាញក្នុងទំព័រដែលដាក់ភ្ជាប់មកជាមួយដោយរៀបរាប់តាមតុលាការ លេខសំណុំរឿង ករណី និងការចោទប្រកាន់។

## ហេតុអ្វីបានជាតុលាការកំពុងលុបចោលនូវការផ្តន្ទាទោសទាំងនេះ?

មានគីមីវិទូម្នាក់ឈ្មោះ សុនចា ហ្វារាក (Sonja Farak) បានប្រព្រឹត្តិនូវអំពើខុសឆ្គងយ៉ាងធ្ងន់ធ្ងរពាក់ព័ន្ធនឹងការងាររបស់គាត់នៅឯមន្ទីរ ពិសោធន៍គ្រឿងញៀនរបស់រដ្ឋ។ សំណុំរឿងរបស់លោក-អ្នកមានការផ្តន្ទាទោសមួយ ឬច្រើនជាងមួយដែលបានរងផលប៉ះពាល់ដោយ

ទង្វើរបស់លោកស្រី Farak។ ឥឡូវ តុលាការបានលុបចោលការផ្តន្ទាទោសទាំងនោះហើយ។ ការលុបចោលនេះគឺផ្តាច់ព្រ័ត្រ និងជាអចិន្ត្រៃយ៍ ដែលមានន័យថា លោក-អ្នកនឹងមិនអាចត្រូវគេផ្តន្ទាទោសម្តងទៀតឡើយចំពោះករណីណាដែលត្រូវបានគេលុបចោល។

## តើមានអ្វីកើតឡើងបន្ទាប់ទៀត?

ឯកសារបទឧក្រិដ្ឋរបស់លោក-អ្នកត្រូវបានគេធ្វើបច្ចុប្បន្នភាពដើម្បីលុបចោលការផ្តន្ទាទោសនានា។ ការលុបចោលនូវការផ្តន្ទាទោសអាចផ្តល់ផលប្រយោជន៍សំខាន់ៗ ដល់លោក-អ្នកទាក់ទងទៅនឹងការងារ លំនៅដ្ឋាន ឥន្ទ្រាប្រវេសន៍ និងអ្វីៗ ផ្សេងទៀត។

ទោះជាយ៉ាងណាក៏ដោយ កំណត់ត្រាឯកសាររបស់លោក-អ្នកមិនទាន់ត្រូវបានគេបិទផ្លិតនោះទេ។ លោក-អ្នកអាចរកឃើញព័ត៌មានបន្ថែមទៀតអំពីការបិទផ្លិតកំណត់ត្រារបស់លោក-អ្នកនៅ **www.masslegalhelp.org/cori**។

លើសពីនេះទៅទៀត លោក-អ្នកប្រហែលជាអាចមានការចោទប្រកាន់ផ្សេងទៀតនៅក្នុងសំណុំរឿងជាមួយគ្នានេះដែរ ដែលពុំទាន់បានលុបចោលនៅឡើយ ហើយដែលនឹងស្ថិតនៅក្នុងឯកសាររបស់លោក-អ្នក។ លោក-អ្នកប្រហែលជាចង់ពិភាក្សាជាមួយមេធាវីណាម្នាក់ដើម្បីសួរនាំមើល ថាតើការផ្តន្ទាទោសទាំងនោះអាចនឹងត្រូវគេលុបចោលបាន ឬអត់។

លោក-អ្នកក៏ប្រហែលជាបានបង់ប្រាក់ដោយសារតែការផ្តន្ទាទោសទាំងនោះ ដូចជាការផាកពិន័យ ថ្លៃតុលាការ ថ្លៃអាជ្ញាអង្កេត ឬប្រាក់បដិទាន។ លោក-អ្នកប្រហែលជាចង់និយាយជាមួយមេធាវីណាម្នាក់ អំពីថាតើលោក-អ្នកមានប្រាក់កាក់ណាដែលអាចត្រូវគេប្រគល់ជូនលោក-អ្នកវិញដែរ ឬអត់។

បើលោក-អ្នកមានសំណួរអ្វីមួយអំពីលិខិតនេះ រួមទាំងវិធីរកមេធាវីម្នាក់ដើម្បីឱ្យជួយ លោក-អ្នកអាចទាក់ទងទៅគណៈកម្មការសេវាកម្មសម្រាប់មេធាវីសាធារណៈ (ជាស្ថាប័នអ្នកការពារក្តីសាធារណៈរបស់រដ្ឋ) ដោយទូរស័ព្ទសម្ងាត់ទៅបណ្តាញសំណុំរឿងនៅមន្ទីរពិសោធន៍គ្រឿងញៀន តាមលេខ **888-999-2881** ឬចូលទៅគេហទំព័រ **www.publiccounsel.net/dlclu**។ លោក-អ្នកក៏អាចឃើញព័ត៌មាននៅលើគេហទំព័ររបស់តុលាការ: **www.mass.gov/courts/druglab**.

ដោយសេចក្តីរាប់អាន,

ហ្វ្រែង ហ្គាហ្ស៊ីអាណូ (Frank M. Gaziano)
ចៅក្រមជាសហការី